ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤០៤ អយក.ប្រក

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់រូបសញ្ញាអប់រំ យុវជន និងកីឡា អក្សរកាត់របស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងអក្សរកាត់ប្រើលើក្បាលលិខិតរដ្ឋបាលផ្លូវការក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២៥ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសញ្ញាខ្ទាស់លើអាវ ឬក្រមាពានាសម្រាប់មន្ត្រីអប់រំ ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីការប្រើប្រាស់រូបសញ្ញាអប់រំ យុវជន និងកីឡា អក្សរកាត់របស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងអក្សរកាត់ប្រើលើក្បាលលិខិតរដ្ឋបាលផ្លូវការក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

## ជំពូកទី២
## ការប្រើប្រាស់រូបសញ្ញាអប់រំ យុវជន និងកីឡា
## និងការទទួលខុសត្រូវ

**ប្រការ២ .-**

រូបសញ្ញាអប់រំ យុវជន និងកីឡា ដូចមានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣២៥ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៧ ស្ដីពីរូបសញ្ញាអប់រំ យុវជន និងកីឡា សញ្ញាសក្តិ ឯកសណ្ឋាន និងសញ្ញាខ្វាស់លើអាវ ឬក្រមាពានាសម្រាប់មន្ត្រីអប់រំ ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម និងក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ សម្រាប់ការងាររដ្ឋបាលមួយចំនួន ដូចខាងក្រោម៖

- លើក្បាលលិខិតផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា
- លើក្បាលលិខិតផ្លូវការរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- លើការដាក់តាំងលើបដានៃកិច្ចពិធីការផ្សេងៗ។

**ប្រការ៣ .-**

សមាសភាពថ្នាក់ដឹកនាំក្រសួងចាប់ពីអនុរដ្ឋលេខាធិការឡើងទៅ អាចចុះហត្ថលេខាលើលិខិតរដ្ឋបាលផ្សេងៗដែលប្រើប្រាស់ក្បាលលិខិតផ្លូវការមានរូបសញ្ញាអប់រំ យុវជន និងកីឡា។

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើលិខិតរដ្ឋបាលដែលប្រើប្រាស់ក្បាលលិខិតមានរូបសញ្ញាអប់រំ យុវជន និងកីឡាតាមនីតិវិធី ដើម្បីសម្រួលដល់កិច្ចការរដ្ឋបាលមួយចំនួនរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤ .-**

ប្រធានមន្ទីរ ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត អាចចុះហត្ថលេខាលើលិខិតរដ្ឋបាលផ្សេងៗដែលប្រើប្រាស់ក្បាលលិខិតផ្លូវការរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តដែលមានរូបសញ្ញាអប់រំ យុវជន និងកីឡា។

**ប្រការ៥ .-**

រាល់ការដាក់តាំងរូបសញ្ញាអប់រំ យុវជន និងកីឡាក្នុងបដានៃកិច្ចពិធីការផ្សេងៗ ក្រៅពីកម្មវិធីដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់កម្មវិធីថ្នាក់ជាតិ ត្រូវសុំការអនុញ្ញាតជាមុនពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាតាមនីតិវិធី។

រាល់ការដាក់តាំងរូបសញ្ញាអប់រំ យុវជន និងកីឡាក្នុងបដានៃកិច្ចពិធីការផ្សេងៗ ក្រៅពីកម្មវិធីដែលរៀបចំដោយមន្ទីរអប់រំ យុវជន និងកីឡា សម្រាប់កម្មវិធីនៅថ្នាក់ក្រោមជាតិ ត្រូវមានការអនុញ្ញាតជាមុនពីថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តដែលរៀបចំកម្មវិធីនោះតាមនីតិវិធី។

**ប្រការ៦ .-**

គ្រប់ការដាក់តាំងបង្ហាញរូបសញ្ញាអប់រំ យុវជន និងកីឡាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយគ្មានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ឬមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តាមនីតិវិធីជាទង្វើខុសច្បាប់។

**ប្រការ៧ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានយករូបសញ្ញាអប់រំ យុវជន និងកីឡាទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមានលើផលប៉ះពាល់ដែលកើតចេញពីការប្រើប្រាស់នោះ។

**ប្រការ៨ .-**

រូបសញ្ញាអប់រំ យុវជន និងកីឡា ប្រើលើក្បាលលិខិតផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្បាលលិខិតផ្លូវការរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត មានដូចក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

## ជំពូកទី៣
## ការប្រើប្រាស់អក្សរកាត់

**ប្រការ៩ .-**

ឈ្មោះជាអក្សរកាត់របស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា សម្រាប់សរសេរនៅលើក្បាលលិខិតរដ្ឋបាលផ្លូវការ ត្រូវបានកំណត់មានដូចក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ១០ .-**

អក្សរកាត់របស់ការិយាល័យក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវបានកំណត់មានដូចក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ១១ .-**

ប្រភេទអក្សរកាត់លិខិតដែលត្រូវបានកំណត់សរសេរលើក្បាលលិខិតរដ្ឋបាលផ្លូវការ មានដូចក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**ប្រការ១២ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានយករូបសញ្ញាអប់រំ យុវជន និងកីឡាទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡាតាមគ្រប់រូបភាពដែលនាំឱ្យប៉ះពាល់ដល់វិស័យអប់រំ យុវជន និងកីឡា ត្រូវបញ្ឈប់ការប្រើប្រាស់ជាបន្ទាន់ក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ១៣ .-**

ក្រសួងអប់រំ យុវជន និងកីឡា នឹងមានចំណាត់ការតាមផ្លូវច្បាប់ជាធរមាន ចំពោះបុគ្គលណាដែលនៅតែបន្តប្រើប្រាស់រូបសញ្ញាអប់រំ យុវជន និងកីឡាដោយគ្មានការអនុញ្ញាត ឬក្នុងចេតនាមិនល្អណាមួយចំពោះក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ១៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥ .-**

អគ្គនាយកនៃអគ្គនាយដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត គ្រឹះស្ថានឧត្តមសិក្សា និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- រដ្ឋបាលរាជធានី ខេត្ត

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- ដូចប្រការ១៥

"ដើម្បីអនុវត្ត"

- ឯកសារ កាលប្បវត្តិ នា.នីតិកម្ម/នា.រដ្ឋបាល

ឧបសម្ព័ន្ធទី១ នៃ

ប្រកាសលេខ ៤១៥ អយក.ប្រកចុះថ្ងៃ សុក្រ ៧រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១ ស្តីពីកំណត់អំពីការប្រើប្រាស់រូបសញ្ញាក្រសួងអប់រំ យុវជន និងកីឡា អក្សរកាត់របស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងអក្សរកាត់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

## រូបសញ្ញាក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងអប់រំ យុវជន និងកីឡា *

# ក្បាលលិខិតរបស់ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ:..............................អយក.

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

KINGDOM OF CAMBODIA
Nation Religion King

MINISTRY OF EDUCATION, YOUTH AND SPORT
No :.......................................................MoEYS/Adm

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងអប់រំយុវជននិងកីឡា

80 Blvd. Preah Norodom, Phnom Penh, Cambodia. Tel: (855-23) 220 673 / 220 304 Fax: (855-23) 217 250 / 212 512
E-mail: info@moeys.gov.kh / administration@moeys.gov.kh Website: www.moeys.gov.kh

# ក្បាលលិខិតរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ**

**លេខ:..................អយកត.**

អាសយដ្ឋានៈ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: 012 702 838 / 077 45 99 91
អ៊ីមែល: phnom.penh@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

# ក្បាលលិខិតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្ដាល

លេខ:..........................អយកខ.

អាសយដ្ឋាន: ផ្លូវលេខ១០៦ ក្រុងតាខ្មៅ ខេត្តកណ្ដាល កម្ពុជា

ទូរស័ព្ទ: 012 966 632 / 098 545 356

អ៊ីមែល: kandal@moeys.gov.kh

គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម
លេខ:..........................អយកខ.

អាសយដ្ឋាន: ក្រុងកំពង់ចាម ខេត្តកំពង់ចាម កម្ពុជា
អ៊ីមែល: kampong.cham@moeys.gov.kh
ទូរស័ព្ទ: 077 945 559
គេហទំព័រ: www.moeys.gov.kh

vi

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង

លេខ:.....................អយកខ.

អាសយដ្ឋាន: ដំណាក់ហ្លួង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កម្ពុជា ទូរស័ព្ទ: 053 732 231

អ៊ីមែល: battambang@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ

លេខ:.................................អយកខ.

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងអប់រំយុវជននិងកីឡា *

អាសយដ្ឋាន: ក្រុងដូនកែង ខេត្តតាកែវ កម្ពុជា
ទូរស័ព្ទ: 012 884 911 / 017 667 525
អ៊ីមែល: takeo@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង
លេខ:..........................អយកខ.

អាសយដ្ឋាន: ក្រុងព្រៃវែង ខេត្តព្រៃវែង កម្ពុជា
ទូរស័ព្ទ: 043 210 393 / 097 777 8803
អ៊ីមែល: prey.veng@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ

លេខ:..........................អយកខ.

អាសយដ្ឋាន: ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កម្ពុជា
ទូរស័ព្ទ: 016 622 045 / 010 284 537
អ៊ីមែល: kampong.speu@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ឆ្នាំង
លេខ:..........................អយកខ.

អាសយដ្ឋាន: ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កម្ពុជា
អ៊ីមែល: kampong.chnang@moeys.gov.kh
ទូរស័ព្ទ: 026 774 328 / 092 388 676
គេហទំព័រ: www.moeys.gov.kh

xi

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត
លេខ:..................អយកខ.

អាសយដ្ឋាន: ក្រុងកំពត ខេត្តកំពត កម្ពុជា
ទូរស័ព្ទ: 033 210 573
អ៊ីមែល: kampot@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ
លេខ:..........................អយកខ.

អាសយដ្ឋាន: ផ្លូវជាតិលេខ០៦ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ កម្ពុជា ទូរស័ព្ទ: 062 210 379
អ៊ីមែល: kampong.thom@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង
លេខ:..........................អយកខ.

អាសយដ្ឋាន: ក្រុងស្វាយរៀង ខេត្តស្វាយរៀង កម្ពុជា ទូរស័ព្ទ: 044 715 391
អ៊ីមែល: svay.rieng@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រចេះ
លេខ:..........................អយកខ.

អាសយដ្ឋាន: ផ្លូវព្រះសីហនុ ក្រុងក្រចេះ ខេត្តក្រចេះ កម្ពុជា
ទូរស័ព្ទ: 072 971 448 / 072 971 683
អ៊ីមែល: kratie@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

XV

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តពោធិ៍សាត់
លេខ:..............................អយកខ.

អាសយដ្ឋាន: ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កម្ពុជា
ទូរស័ព្ទ: 052 740 857 / 012 373 888
អ៊ីមែល: pursat@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ

លេខ:..............................អយកខ.

អាសយដ្ឋាន: ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កម្ពុជា
ទូរស័ព្ទ: 012 941 399 / 092 159 566
អ៊ីមែល: banteay.meanchey@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
លេខ:..................អយកខ.

អាសយដ្ឋាន: មណ្ឌលរដ្ឋបាលមន្ទីរខេត្តសៀមរាបកម្ពុជា ទូរស័ព្ទ: 063 210 740
អ៊ីមែល: siem.reap@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ
លេខ:..................អយកខ.

អាសយដ្ឋាន: វិថីឯករាជ្យ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កម្ពុជា ទូរស័ព្ទ: 098 855 487 / 015 660 702
អ៊ីមែល: sihanoukville@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តកែប
លេខ:.................................អយកខ.


អាសយដ្ឋាន: ផ្លូវ៣៣A ក្រុងកែប ខេត្តកែប កម្ពុជា
អ៊ីមែល: kep@moeys.gov.kh
ទូរស័ព្ទ: 017 889 298 / 092 151 451
គេហទំព័រ: www.moeys.gov.kh


xx

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តប៉ៃលិន
លេខ:..................អយកខ.

អាសយដ្ឋាន: ក្រុងប៉ៃលិន ខេត្តប៉ៃលិន កម្ពុជា
អ៊ីមែល: pilin@moeys.gov.kh
ទូរស័ព្ទ: 016 572 040
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តកោះកុង
លេខ:..........................អយកខ.

អាសយដ្ឋាន: ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កម្ពុជា
ទូរស័ព្ទ: 016 333 845 / 096 661 6263
អ៊ីមែល: koh.kong@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ទឹងត្រែង
លេខ:.....................អយកខ.

អាសយដ្ឋាន: ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កម្ពុជា
ទូរស័ព្ទ: 076 660 8591 / 074 210 133
អ៊ីមែល: stung_treng@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តមណ្ឌលគិរី
លេខ:..........................អយកខ.

អាសយដ្ឋាន: ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កម្ពុជា
អ៊ីមែល: mondulkiri@moeys.gov.kh
ទូរស័ព្ទ: 012 998 028 / 012 766 090
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី

លេខ:..........................អយក.

អាសយដ្ឋាន: ក្រុងបានលុង ខេត្តរតនគិរី កម្ពុជា
ទូរស័ព្ទ: 075 974 093
អ៊ីមែល: ratanakiri@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះវិហារ
លេខ:.................អយកខ.

អាសយដ្ឋាន: ផ្លូវកោះកេរ ក្រុងព្រះវិហារ ខេត្តព្រះវិហារ កម្ពុជា ទូរស័ព្ទ: 078 366 627 / 012 619 385
អ៊ីមែល: preah.vihear@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តឧត្តរមានជ័យ

លេខ:..................អយកខ.

អាសយដ្ឋាន: ក្រុងសំរោង ខេត្តឧត្តរមានជ័យ កម្ពុជា
ទូរស័ព្ទ: 099 897 923 / 012 313 653
អ៊ីមែល: oddarmeancheay@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ

លេខៈ..........................អយកខ.

អាសយដ្ឋានៈ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កម្ពុជា
ទូរស័ព្ទ: 012 418 929 / 092 595 388
អ៊ីមែលៈ tbong.khmum@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh

ឧបសម្ព័ន្ធទី២ នៃ

ប្រកាសលេខ ៤១៥ អយក.ប្រកចុះថ្ងៃសុក្រ ៧រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២១ ស្ដីពីកំណត់អំពីការប្រើប្រាស់រូបសញ្ញាក្រសួងអប់រំ យុវជន និងកីឡា អក្សរកាត់របស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងអក្សរកាត់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

**១.អក្សរកាត់សម្រាប់សរសេរនៅលើក្បាលលិខិតរដ្ឋបាលផ្លូវការរបស់អង្គភាពថ្នាក់កណ្ដាល ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា** ត្រូវបានកំណត់មានដូចខាងក្រោម៖

| | | |
|---|---|---|
| ❖ **អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ** | : | អគរហ |
| - នាយកដ្ឋានរដ្ឋបាល | : | រប |
| - នាយកដ្ឋានបុគ្គលិក | : | បល |
| - នាយកដ្ឋានហិរញ្ញវត្ថុ | : | ហវ |
| - នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន | : | ពអស៊ |
| - នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | : | បវព |
| - នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | : | ទវអ |
| - នាយកដ្ឋានសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ | : | សទរ |
| - នាយកដ្ឋាននីតិកម្ម | : | នក |
| - នាយកដ្ឋានសំណង់ | : | សណ |
| ❖ **អគ្គាធិការដ្ឋាន** | : | អគធក |
| - នាយកដ្ឋានធានាគុណភាពអប់រំ | : | ធគអ |
| - នាយកដ្ឋាននាយកដ្ឋានកិច្ចការប្រឡង | : | កប្រឡ |
| - អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | : | អរហ |
| ❖ **អគ្គនាយកដ្ឋានអប់រំ** | : | អគអរ |
| - នាយកដ្ឋានអប់រំកុមារតូច | : | អកត |
| - នាយកដ្ឋានបឋមសិក្សា | : | បស |
| - នាយកដ្ឋានអប់រំពិសេស | : | អពស |
| - នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | : | មចទ |
| - នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | : | អកប |
| - នាយកដ្ឋានសុខភាពសិក្សា | : | សស |
| - នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | : | អកស |
| - នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ | : | បវ |
| - នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | : | តទវ |
| - គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ | : | គបច |
| - សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម | : | សគមម |

- ❖ **អគ្គនាយកដ្ឋានឧត្តមសិក្សា** : អគឧស
  - នាយកដ្ឋានឧត្តមសិក្សា : ឧស
  - នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ : សវ
- ❖ **អគ្គនាយកដ្ឋានយុវជន** : អគយវ
  - នាយកដ្ឋានយុវជន : យវ
  - នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល : គម
  - នាយកដ្ឋានសហប្រតិបត្តិការកាយវប្បធម៌ : សក
- ❖ **អគ្គនាយកដ្ឋានកីឡា** : អគកឡ
  - នាយកដ្ឋានអប់រំកាយ និងកីឡា : អកឡ
  - នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត : អកសន
  - មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា : មជហក
  - វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា : វអក
  - នាយកដ្ឋានរៀបចំព្រឹត្តិការណ៍កីឡា : រពកឡ
  - មជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យា និងស្ថិតិកីឡា : មជពសក
- ❖ **អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ** : អគបផ
  - នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ : ពអ
  - នាយកដ្ឋានគោលនយោបាយ : គប
  - នាយកដ្ឋានផែនការ : ផក
  - នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ : ពវ
- ❖ **គ្រឹះស្ថានឧត្តមសិក្សាក្រោមឱវាទក្រសួង និងអង្គភាពផ្សេងៗ**
  - សាកលវិទ្យាល័យភូមិន្ទភ្នំពេញ : សភភព
  - សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច: សភនវស
  - សាកលវិទ្យាល័យជាតិគ្រប់គ្រង : សជគ
  - សាកលវិទ្យាល័យស្វាយរៀង : សសរ
  - សាកលវិទ្យាល័យជាតិមានជ័យ : សជមជ
  - សាកលវិទ្យាល័យជាតិបាត់ដំបង : សជបដ
  - សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ : សជសក
  - សាកលវិទ្យាល័យក្រចេះ : សកច
  - វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា : វបក
  - វិទ្យាស្ថានជាតិអប់រំ : វជអ
  - វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ : វបកស
  - វិទ្យាស្ថានជាតិអប់រំពិសេស : វជអព
  - វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ : វគភ
  - វិទ្យាស្ថានគរុកោសល្យបាត់ដំបង : វគប

- វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល : វបកឈ

- នាយកដ្ឋានសវនកម្មផ្ទៃក្នុង : សផក
- អង្គភាពលទ្ធកម្ម : អល

❖ **មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ**

- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម : មគភ.កច
- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តតាកែវ : មគភ.តក
- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង : មគភ.ពវ
- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្ដាល : មគភ.កណ
- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង : មគភ.សត

❖ **សាលាគរុកោសល្យភូមិភាគនិងវិក្រឹតការខេត្ត**

- សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ចាម : សគវ.កច
- សាលាគរុកោសល្យនិងវិក្រឹតការ ហ៊ុន សែន ខេត្តព្រៃវែង : សគវ.ហស.ពវ
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តតាកែវ : សគវ.តក
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តកណ្ដាល : សគវ.កណ
- សាលាគរុកោសល្យនិងវិក្រឹតការ ហ៊ុន សែន ខេត្តកំពង់ធំ: សគវ.ហស.កធ
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តសៀមរាប : សគវ.សរ
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តក្រចេះ : សគវ.ក្រច
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តស្វាយរៀង : សគវ.ស្វរ
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពត : សគវ.កព
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តព្រះសីហនុ : សគវ.សន
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ឆ្នាំង : សគវ.កឆ
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តពោធិ៍សាត់ : សគវ.ពស
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តបន្ទាយមានជ័យ : សគវ.បជ
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តព្រះវិហារ : សគវ.ពហ
- សាលាគរុកោសល្យនិងវិក្រឹតការខេត្តកំពង់ស្ពឺ : សគវ.កស

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងអប់រំ យុវជន និងកីឡា *

ឧបសម្ព័ន្ធទី៣ នៃ

ប្រកាសលេខ៤១៥ អយក.ប្រកចុះថ្ងៃសុក្រ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១ ស្តីពីកំណត់អំពីការប្រើប្រាស់រូបសញ្ញាក្រសួងអប់រំ យុវជន និងកីឡា អក្សរកាត់របស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងអក្សរកាត់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

អក្សរកាត់របស់ការិយាល័យក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវបានកំណត់ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល : រប
- ការិយាល័យបុគ្គលិក និងបណ្តុះបណ្តាល : បុប
- ការិយាល័យអប់រំកុមារតូច : អកត
- ការិយាល័យបឋមសិក្សា : បស
- ការិយាល័យមធ្យមសិក្សា និងចំណេះទូទៅ : មចទ
- ការិយាល័យអប់រំក្រៅប្រព័ន្ធ : អកប
- ការិយាល័យប្រឡង : ប្រឡ
- ការិយាល័យគណនេយ្យ សម្ភារៈនិងទ្រព្យសម្បត្តិរដ្ឋៈ គន
- ការិយាល័យផែនការ : ផក
- ការិយាល័យកីឡា : កឡ
- ការិយាល័យយុវជន : យវ
- ការិយាល័យអធិការកិច្ច : អធក

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលមានការិយាល័យ ដូចខាងក្រោម ត្រូវប្រើអក្សរកាត់៖

- ការិយាល័យរដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាលៈ របុប
- ការិយល័យយុវជន និងកីឡា : យក

ឧបសម្ព័ន្ធទី៤ នៃ

ប្រកាសលេខ ៤១៥ អយក.ប្រកចុះថ្ងៃសុក្រ ៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១ ស្ដីពីកំណត់អំពីការប្រើប្រាស់រូបសញ្ញាក្រសួងអប់រំ យុវជន និងកីឡា អក្សរកាត់របស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងអក្សរកាត់របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

## ប្រភេទអក្សរកាត់ដែលត្រូវបានកំណត់សរសេរលើលិខិតរដ្ឋបាលមាន៖

| | | |
|---|---|---|
| - សេចក្ដីជូនដំណឹង | : | សជណ |
| - សេចក្ដីណែនាំ | : | សណន |
| - លិខិតឧទ្ទេសនាម | : | ឧទន |
| - លិខិតបញ្ជាបេសកកម្ម | : | បសក |
| - លិខិតបង្គាប់ការ | : | បក |
| - លិខិតផ្ទេរសិទ្ធិ | : | ផស |
| - លិខិតថតចម្លង | : | ចល |
| - ដីកាអម | : | ដអ |
| - ដីកាបញ្ជូន | : | ដប |